ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥

# <u>សេចក្តីជូនដំណឹង</u>

## កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពី "ការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តន៍អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (INDC)"

ក្រសួងបរិស្ថានមានកិត្តិយសសូមជម្រាបជូនសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ ទាំងអស់ឱ្យបានជ្រាបថា ក្រសួងនឹងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី **ការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តន៍អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ** (Cambodia's Intended Nationally Determined Contribution: Cambodia's INDC) នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី វេលាម៉ោង ៨:០០ ព្រឹក ក្រោមអធិបតីភាពរបស់ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន។

កិច្ចប្រជុំពិគ្រោះយោបល់នេះ មានគោលបំណងប្រមូលមតិយោបល់ និងអនុសាសន៍នានាពីគ្រប់បណ្តាក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ទៅលើរបាយការណ៍ការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តន៍អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលជារបាយការណ៍សំខាន់បញ្ជាក់អំពីការរួមចំណែករបស់ភាគីកម្ពុជាក្នុងការឆ្លើយតបនឹងសេចក្តីអំពាវនាវរបស់អនុសញ្ញានេះ ក្នុងគោលបំណងជំរុញឱ្យពិភពលោកធ្វើសកម្មភាពដោះស្រាយការប្រែប្រួលអាកាសធាតុ។ បន្ទាប់មក របាយការណ៍នេះ នឹងត្រូវបានបញ្ជូនទៅកាន់លេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ មុនការរៀបចំសន្និសីទកំពូលបណ្តាភាគីជាសមាជិកនៃអនុសញ្ញា លើកទី២១ នាដើមខែធ្នូ ឆ្នាំ២០១៥ខាងមុខ នៅទីក្រុងប៉ារីស។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមអញ្ជើញបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ ចូលរួមផ្តិតយកព័ត៌មាន និងទិដ្ឋភាពក្នុងកិច្ចប្រជុំនេះ តាមការគួរ។

សម្រាប់អ្នកសារព័ត៌មាន សូមចុះឈ្មោះចូលរួមយកព័ត៌មានឱ្យបានមុន តាមរយៈសារលេខទូរស័ព្ទ ០៧៧ ៥៣ ៥៣ ៩២ ឬ reaksmey.neou@camclimate.org.kh។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ឯកឧត្តម **សៅ សុភាព** នាយកខុទ្ទកាល័យ និងជាអ្នកនាំពាក្យក្រសួងបរិស្ថាន តាមរយៈលេខទូរស័ព្ទ ០១២ ៩៧១ ២២២ ឬ saosopheap@yahoo.com។

# សេចក្តីព្រាងរបៀបវារៈ

| ពេលវេលា | កម្មវិធី/ប្រធានបទ | វាគ្មិន |
|---|---|---|
| ៧:០០-៨:៣០ | ការចុះឈ្មោះ | |
| ៨:៣០-៩:០០ | - សុន្ទរកថាស្វាគមន៍<br><br><br>- សុន្ទរកថាបើកអង្គប្រជុំ | - ឯកឧត្តម**ទិន ពន្លក**<br>អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព<br>- ឯកឧត្តម**សាយ សំអាល់**<br>រដ្ឋមន្ត្រីក្រសួងបរិស្ថាន |
| ៩:០០-៩:១០ | គោលបំណង និងរបៀបវារៈនៃ អង្គប្រជុំ | លោកស្រី នេត បារ៉ូដា<br>មន្ត្រីនាយកដ្ឋានប្រែប្រួល អាកាសធាតុ |
| ៩:១០-៩:៤០ | ដំណើរការរៀបចំINDC និងស្ថានភាពនៃការដាក់ស្នើ | - លោកបណ្ឌិត **សូឌី សាម៉ា**<br>( Dr. Sudhir Sharma )<br>-តំណាងដៃគូអភិវឌ្ឍន៍ UNEP DTU |
| ៩:៤០-១០:១០ | ដំណើរការរៀបចំINDCរបស់ប្រទេសកម្ពុជា | លោក **ស៊ុំ ធី**<br>ប្រធាននាយកដ្ឋាន ប្រែប្រួលអាកាសធាតុ |
| ១០:១០-១០:៣០ | សម្រាកពិសារអាហារសម្រន់ | |
| ១០:៣០-១១:២០ | -បន្សាំនិងសកម្មភាពអាទិភាព<br>- ការពិភាក្សា | លោក **ជា ច័ន្ទន័ធូ**<br>ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកទេស |
| ១១:២០-១២:១០ | -ការកាត់បន្ថយ និងការចូលរួម ចំណែក<br>- ការពិភាក្សា | លោក **អ៊ុយ កាម៉ាល**<br>អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| ១២:១០-១៣:៣០ | សម្រាកពិសារអាហារថ្ងៃត្រង់ | |
| ១៣:៣០-១៤:៣០ | -ដំណើរការរៀបចំផែនការ និង ការអនុវត្ត<br>- ការពិភាក្សា | លោក **សូផា សុគន្ធណារុង្គ**<br>មន្ត្រីនាយកដ្ឋានប្រែប្រួល អាកាសធាតុ |
| ១៤:៣០-១៥:០០ | សម្រាកពិសារអាហារសម្រន់ | |
| ១៥:០០-១៦:០០ | - វិធីសាស្ត្រចាំបាច់សម្រាប់អនុវត្ត<br>- ការពិភាក្សា | លោក **ស៊ុំ ធី** |
| ១៦:០០-១៦:៣០ | ការពិភាក្សា | **អ្នកចូលរួមទាំងអស់** |
| ១៦:៣០-១៧:០០ | សេចក្តីសង្ខេបលទ្ធផល និងបិទ អង្គប្រជុំ | ឯកឧត្តម **ទិន ពន្លក** |

## កំណត់សម្គាល់៖

### ១) តើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ គឺជាអ្វី?

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានអនុម័តនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ១៩៩២ នៅទីក្រុងញូវយ៉ក និងបានចុះហត្ថលេខានៅក្នុងកិច្ចប្រជុំកំពូលពិភពលោក ឆ្នាំ១៩៩២ នៅទីក្រុងរីយ៉ូដឺហ្សានេរ៉ូនៃប្រទេសប្រេស៊ីល ដោយប្រទេសជាង១៥០ និងសហគមន៍អឺរ៉ុប។ គោលបំណងចម្បងនៃអនុសញ្ញានេះគឺ "ធ្វើឱ្យមានស្ថិរភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់ក្នុងបរិយាកាស នៅត្រឹមកម្រិតមួយដែលអាចទប់ស្កាត់ការរំខានប្រកបដោយគ្រោះថ្នាក់ពីសកម្មភាពមនុស្សមកលើប្រព័ន្ធអាកាសធាតុ"។ អនុសញ្ញានេះចែងអំពីការប្តេជ្ញាចិត្តរបស់បណ្តាភាគីទាំងអស់។ អនុសញ្ញានេះ ចូលជាធរមាននៅខែមីនា ឆ្នាំ១៩៩៤។ នៅឆ្នាំ១៩៩៧ អនុសញ្ញានេះបានអនុម័តឱ្យមានពិធីសារក្យូតូ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩៥ ក្រោយពីការបង្កើតក្រសួងបរិស្ថានបានពីរឆ្នាំ។

### ២) តើការចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តន៍អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (Cambodia's INDC) គឺជាអ្វី?

នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) បណ្តាប្រទេសនៅទូទាំងពិភពលោក បានប្តេជ្ញាចិត្តបង្កើតកិច្ចព្រមព្រៀងអាកាសធាតុអន្តរជាតិថ្មីមួយ ដែលនឹងត្រូវបូកសរុបនៅក្នុងសន្និសីទបណ្តាភាគីលើកទី២១ (CoP21) នៃUNFCCC នៅទីក្រុងប៉ារីស ប្រទេសបារាំង នៅខែធ្នូ ឆ្នាំ២០១៥ ខាងមុខនេះ។ ក្នុងការរៀបចំរបាយការណ៍នេះ បណ្តាប្រទេសនានា បានឯកភាពបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ នៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិថ្មីមួយ ហៅថា "**ការចូលរួមចំណែក ដើម្បីអនុវត្តន៍អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDC)**"។ ការរួមចំណែកជាសកលនេះ បាននាំមកនូវអភិក្រមពីថ្នាក់ក្រោមទៅលើ ដើម្បីរៀបចំគោលជំហររបស់ប្រទេសមួយដោយផ្អែកលើស្ថានភាពជាក់ស្តែង និងតាមប្រព័ន្ធថ្នាក់ជាតិ ដើម្បីកាត់បន្ថយកំណើនសីតុណ្ហភាពមធ្យមរបស់សកលលោក ត្រឹម ២អង្សាសេ។

ប្រទេសកម្ពុជាទទួលស្គាល់តម្រូវការឱ្យប្រទេសទាំងអស់ចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហើយដើម្បីរួមចំណែកសម្រេចបាននូវគោលដៅរបស់ UNFCCC នេះ ប្រទេសកម្ពុជាមានក្តីសោមនស្សក្នុងការរៀបចំរបាយការណ៍ចូលរួមចំណែករបស់កម្ពុជា ដើម្បីអនុវត្តន៍អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (INDC) ឱ្យបានមុនកិច្ចប្រជុំកំពូលបណ្តាភាគីលើកទី២១ នៅទីក្រុងប៉ារីស។

ក្នុងនាមជាប្រទេសបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិចតួច ប៉ុន្តែទទួលរងគ្រោះខ្លាំងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការរួមចំណែករបស់កម្ពុជាចាំបាច់ត្រូវបន្សុីទៅនឹងអាទិភាពអភិវឌ្ឍន៍របស់ប្រទេស។ ដូច្នេះ របាយការណ៍ INDC នឹងរួមបញ្ចូលសមាសភាគបន្សុាំ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដោយផ្អែកលើស្ថានភាពប្រទេសជាតិ និងបន្សុីជាមួយសេចក្តីសម្រេចរបស់ UNFCCC 1/CP.19 and 1/CP.20។

Kingdom of Cambodia
Nation Religion King

Ministry of Environment

Phnom Penh, 14 September 2015

# Announcement

## Consultation Meeting on

## Cambodia's Intended Nationally Determined Contribution

Ministry of Environment has the honor to inform the public, national and international press that the Ministry will organize a consultation meeting on **Cambodia's Intended Nationally Determined Contribution (Cambodia's INDC**) to be held on 16 September 2015 at Himawari Hotel, 8:00am and presided over by H.E. **Say Samal**, the Minister of Environment.

The meeting aims to collect all inputs and recommendations from line ministries, agencies and stakeholders for the Cambodia's INDC to be submitted to the Secretariat of United Nations Framework Convention on Climate Change (UNFCCC) in prior to its 21st Conference of the Parties (CoP21) taking place in coming December 2015 at Paris, France. The Cambodia's INDC is one of the main documents presenting Cambodia's contribution to the globe's Call for Climate Action.

Kindly be informed that attendance to this meeting will be by invitation only. Media representatives are invited to cover the meeting by registration through 077 53 53 92 or reaksmey.neou@camclimate.org.kh.

For more information, kindly contact **H.E. Sao Sopheap**, Chief of the Minister's Cabinet and spoke person through 012 971 222 or saosopheap@yahoo.com.

# Tentative Agenda

| Time | Topic | Speaker |
|---|---|---|
| 7:00-8:30 | Registration | |
| 8:30-9:00 | Welcome remarks<br><br>Opening remarks | H.E. Tin Ponlok, Secretary General, National Council for Sustainable Development<br>H.E. Say Samal, Minister of Environment |
| 8:15-8:25 | Objectives and agenda of the workshop | Ms. Neth Baroda |
| 8:25-9:00 | INDC development process and Status of submission | Dr. Sudhir Sharma, UNEP DTU Partnership |
| 9:00-9:30 | Cambodia's INDC development Process | Mr. Sum Thy |
| 9:30-10:00 | Tea/Coffee | |
| 10:00-11:00 | - Adaption and Priority Action<br>- Discussion and comments | Mr. Chea Chanthou |
| 11:00-12:00 | - Mitigation and contribution<br>- Discussion and comments | Mr. Uy Kamal |
| 12:00-13:30 | Lunch | |
| 13:30-14:30 | - Planning and implementation process<br>- Discussion and comments | Mr. Ma Chansethea |
| 14:30-15:00 | Tea/Coffee | |
| 15:00-16:00 | - Means of Implementation<br>- Discussion and comments | Mr. Sum Thy |
| 16:00-16:30 | General discussion and comments | All |
| 16:20-17:00 | Workshop summary and closing | H.E. Tin Ponlok |

**Notes:**

**1) What is United Nations Framework Convention on Climate Chang (UNFCCC)?**

The Convention was adopted on 9 May 1992 in New York and signed at the 1992 Earth Summit in Rio de Janeiro, Brazil by more than 150 countries and the European Community. Its ultimate objective is the "stabilization of greenhouse gas concentrations in the atmosphere at a level that would prevent dangerous anthropogenic interference with the climate system". It contains commitments for all Parties. The Convention entered in force in March 1994. In 1997, the UNFCCC adopted the Kyoto Protocol. Cambodia signed the UNFCCC on 13 December 1995, just two years after the establishment of the Ministry of Environment

**2) What is Cambodia's Intended Nationally Determine Contribution (Cambodia's INDC)?**

Under the U.N. Framework Convention on Climate Change (UNFCCC), all countries across the globe made a commitment to develop a new international climate agreement by the conclusion of the Paris Climate Summit in December 2015. During previous climate negotiations, countries agreed to outline their commitments to reducing greenhouse gas emissions under a global agreement, with the so-called **Intended Nationally Determined Contributions (INDCs)**. These global contributions bring together bottom-up approaches, where countries put forward their

positions based on national circumstances, with a top-down system aimed at reducing the average global temperature to 2$^{o}$C.

Cambodia recognises the need for all countries to limit their greenhouse gas emissions, in order to achieve the UNFCCC's objective. To successfully contribute to this global goal, we are extremely pleased to present our Intended Nationally Determined Contribution (INDC) to the United Nations Framework Convention on Climate Change (UNFCCC), ahead of COP 21 in Paris.

As a low emitter and highly vulnerable country to the negative effects of climate change, our contribution is necessarily aligned with our development priorities. The INDC therefore includes both adaptation and mitigation components based on our national circumstances, and in line with UNFCCC decisions 1/CP.19 and 1/CP.20.